# ការសំភាសន៍របស់បងប្រុស សួន សុខុម

កះ អ្នកដែលសំភាសន៍ញ៉ែម សុគន្ធា ខះ អ្នកដែលត្រូវគេសំភាសន៍សួន សុខុម

## ការសង្ខេបរបស់បងប្រុស សួន សុខុម

បងប្រុសសុខុមគាត់ជាបុរសម្នាក់ដែលបានទទួលការអប់រំច្រើន
ហើយគាត់បានបែកពីឪពុក
តាំងពីគាត់នៅក្មេងដោយសារម្តាយរបស់គាត់ទ្រាំនឹងការវ៉ាយដំពីឪពុករបស់គាត់មិនបានក៏សំ រេចចាកចេញពីប្តីហើយនាំយកគាត់នឹងបងប្រុស២នាក់មកជាមួយហើយ
ជីវិតរបស់គាត់ពិបាក
ដោយសារមានតែម្តាយជាអ្នករកស៊ីតែម្នាក់ឯង។តែដោយសារការតស៊ូនឹងព្យាយាមហើយ
គាត់ មានជំនឿលើព្រះយេស៊ូវគ្រីស្ទទើបធ្វើអោយគាត់រីកចំរើនហើយគាត់ឥឡូវជាមគ្គុទេស
ទេសច រណ៍ ហើយរស់នៅដោយរីករាយ។

កះជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់បងសុខុមដែលបានអោយញ៉ុមសំភាសន៍អំពីជីវប្រ វត្តិរបស់បងនាងខ្ញុំឈ្មោះញ៉ែម
សុគន្ធាជាអ្នកសំភាសន៍ជិវប្រវត្តិរបស់បងខុមនៅក្នុងថ្ងៃនេះហើ
យថ្ងៃដែលពួកយើងសំភាសន៍នេះគឺនៅក្នុងថ្ងៃទី១២ខែតុលា ឆ្នាំ២០១៧
ចឹងគឺនៅកន្លែងដែល ញ៉ុមសំភាសន៍បងខុមគឺនៅឃុំថ្មី ក្រុងតាខ្មៅ
ខេត្តកណ្តាល។ហើយចឹងបងសូមប្រាប់ឈ្មោះ ពេញរបស់បង?

ខះបាទខ្ញុំបាទឈ្មោះ សួន សុខុម។

កះហើយបងកើតនៅក្នុងថ្ងៃខែ ឆ្នាំណាដែរ?

ខះញ៉ុមអត់ដឹងថ្ងៃខែឆ្នាំទេ
ដោយសារអីដោយសារម្តាយខ្ញុំនៅក្នុងជំនាន់ប៉ុលពតគាត់អត់បាន កត់ទុកដែរគាត់ភ្លេច
ហើយម៉ាក់ញ៉ុមគាត់ចាំតែឆ្នាំគាត់ប្រាប់ញ៉ុម ញ៉ុមចាំទៅ នៅក្នុងឆ្នាំ១៩៨២

កះចាំហើយបងកើតនៅទីកន្លែងកំណើតនៅទីណាវិញ?

ខះញ៉ុមកើតនៅជំរុំជាយដែនកន្លែងជនភៀសខ្លួននៅប្រទេសថៃ
ព្រំប្រទល់ថៃហើយនឹងខ្មែរ។

កៈគេហៅភូមិឃុំអីគេដែរបង?

ខៈអើញ៉ុមភ្លេចបាត់ហើយអត់ដឹងទេ!!!

កៈតែខេត្តឧត្តរមានជ័យឬក៏បន្ទាយមានជ័យ?

ខៈអើបាទគឺនៅមួយជួរភ្នំដងរែកបាទប្រហែលជានៅឧត្តរមានជ័យហើយដោយសារញ៉ុម
នៅ ទូចដែរញ៉ុមភ្លេចហើយឥឡូវ។

កៈចាំហ្នឹងហើយ។ចឹងបងតើបងសុខុមមានឈ្មោះហៅខាងក្រៅអត់?

ខៈអត់ទេញ៉ុមឈ្មោះអើ ញ៉ុមឈ្មោះនៅក្នុងម៉េចក្រៅចឹង។

កៈចាំចឹងអត់មានអ្នកណាដាក់រហ័សនាមអីពីតូចមកអីអត់ទេហេ៎?

ខៈដាក់ដល់ដេញវ៉ើ។

កៈចឹងបងខុម តើឆ្នាំនេះបងអាយុប៉ុន្មានហើយ?

ខៈប្រហែលជា៣៤ ៣៤ ៣៥ហ្នឹង។

កៈចាំតើបងកើតឆ្នាំខ្មែរជាសត្វអ្វី?

ខៈជាសត្វឆ្កែ។

កៈគេហៅថាឆ្នាំ!!!

ខៈឆ្នាំច។

កៈហ្នឹងហើយឆ្នាំច។ហើយបងរៀនភាសាអ្វីក្រៅពីភាសាខ្មែរដែរអត់?

ខៈបាទញ៉ុមរៀនភាសាអង់គ្លេសនឹងភាសាកូរ៉េ។

កៈចាំហើយគិតថាអង់គ្លេសចេះបានប៉ុន្មានភាគរយដែរ?

ខៈញ៉ុមគិតថាបាន៧០ ទៅ៨០%។

កៈចុះភាសាកូរ៉េ?

ខៈកូរ៉េគិតថាបានប្រហែល៣០ ទៅ៤០ភាគរយតែខានរៀនកូរ៉េយូហើយ
នៅសល់តែ១០ត្រឹម ២០ភាគរយទេ។

ក៖ចាំចឹងបងចេះសរសេរភាសាខ្មែរបានចេះច្បាស់អត់?

ខ៖ហ៊ីច្បាស់ហើយ។

ក៖ចុះភាសាអង់គ្លេស?

ខ៖ច្បាស់ដែរ។

ក៖ចុះកូរ៉េបានប៉ុន្មាន?

ខ៖កូរ៉េក៏ច្បាស់ដែរប៉ុន្តែអត់ស្គាល់ពាក្យច្រើន។

ក៖ហ្ហ៎!!

ខ៖តែបើសរសេរដឹងច្បាស់ហើយដោយ សារស្រួលចង់ងាប់ហ្នឹង!!!

ក៖ចាំចឹងបងតើម្តាយរបស់បងខុមគាត់ឈ្មោះអីគេដែរ?

ខ៖ម្តាយរបស់ខ្ញុំបាទហ្នឹងឈ្មោះ ប៉ូស ស៊ីណាន់។

ក៖ចាំចឹងតើម្តាយរបស់បងសុខុមកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរបង?

ខ៖គាត់កើតនៅថ្ងៃទី០២ ខែមិនា ឆ្នាំ១៩៥២។

ក៖ចាំចឹងតើម្តាយរបស់បងសុខុមមានទីកន្លែងកំណើតនៅឯណាវិញ?

ខ៖គាត់កើតនៅភូមិស្ទឹងជ្រៅ ឃុំដើមមៀន ស្រុកតាខ្មៅ ខេត្តកណ្តាល។

ក៖ចាំចឹងចាំថាអ៊ំស្រីគាត់កើតឆ្នាំខ្មែរឆ្នាំអីគេវិញ?

ខ៖ឆ្នាំជូត កណ្តុរ។

ក៖ចាំហើយតើបងខុមដូចជាមានអនុស្សាវរីយ៍អ្វីខ្លះជាមួយហ្នឹងម្តាយរបស់បង?

ខ៖អនុស្សាវរីយ៍ម៉េចចង់និយាយថាម៉េច?

ក៖ដូចជាអនុស្សាវរីយ៍ក៏ដូចជាការរស់នៅជាមួយគ្នាតើបងមានអ្វីខ្លះជាមួយហ្នឹងម្តាយរបស់បង។

ខ៖ម្តាយរបស់ខ្ញុំគឺជានារីក៏ល្អម្នាក់សំរាប់ខ្ញុំហើយគាត់ស្រលាញ់កូនៗណាស់ហើយអើយគាត់

តែងតែជួយថែរក្សាទំនុកបំរុងគាត់បារម្ភពីកូនគ្រប់បែបយ៉ាងហើយគាត់ល្អគ្រប់បែបយ៉ាងហើយ អើយអនុស្សាវរីយ៍ញ៉ុមបានជូនគាត់ទៅលេងកំពង់សោម នាំជូនគាត់ទៅលេងប្រាសាទអង្គរវត្តហើយញ៉ុមព្យាយាមធ្វើដើរនាគាត់ដើរកំសាន្តច្រើនៗ ដើម្បីអោយជីវិតរបស់គាត់អើអោយស្គាល់ដោយសារពីជំនាន់បុរាណមកគាត់អត់សូវដើរសប្បាយទេ ហើយគាត់គឺជាស្ត្រីល្អសំរាប់ញ៉ុមគា ត់គឺជាស្ត្រីដ៏ល្អ។

កៈអូខេចឹងបងតើដូចជាតើម្តាយបងបានអប់រំទូន្មានប្រៀនប្រដៅដល់បងយ៉ា ងម៉េចដែរ?

ខៈបាទនិយាយអោយចំទៅគាត់បានចង់ម្តាយណាក៏ដូចម្តាយណាដែរ ម្តាយរបស់ខ្ញុំហ្នឹងគាត់ តែងតែចង់អោយកូនហ្នឹងល្អមានគេស្រលាញ់មានគេរាប់អានហើយមានគេចូលចិត្តច្រើនជាពិ សេសហ្នឹងអោយមានមុខមាត់នៅក្នុងសង្គមមានការងារធ្វើមាន និយាយអោយចំគាត់ចង់អោ យកូនមានមុខមានមាត់មានកិត្តិយស។

កៈចាំ!!ចឹងចូលដល់ឪពុករបស់បងខុមវិញម្តងតើឪពុករបស់បងសុខុមឈ្មោះអ្វីដែរ?

ខៈអើគាត់ឈ្មោះ សួន សំអុល។

កៈតើឪពុករបស់បងសុខុមគាត់កើតនៅថ្ងៃខែឆ្នាំណាដែរបង?

ខៈគាត់កើតថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៥១។

កៈតើទីកន្លែងកំណើតរបស់គាត់នៅឯណាវិញ?

ខៈគាត់កើតនៅស្រុកថ្មគោលខេត្តបាត់ដំបង។

កៈតើបងធ្លាប់មានអនុស្សាវរីយ៍អីខ្លះជាមួយឪពុកទេ?

ខៈដូចជាមិនសូវមានទេដោយសារអើពួកខ្ញុំអើយនិយាយទៅពួកគាត់អត់សូវបានមើលថែពួកខ្ញុំទេហើយម្តាយខ្ញុំបានសំរេចចិត្តចាកចិត្តពីគាត់តាំងពីពួកខ្ញុំនៅតូចៗម្ល៉េះ ។កៈចាំ!!ខៈហើយខ្ញុំ អត់មានអនុស្សាវរីយ៍ច្រើនទេ។

កៈ ហើយបងចាំអីគេខ្លះពេលបងនៅជាមួយគាត់ពេលបងនៅទូចៗតើគាត់ជាមនុស្សបែបណាដែរ?

ខៈការពិតគាត់ជាមនុស្សល្អប៉ុន្តែគ្រាន់ថាដោយសារគាត់ខូចពេកគាត់អត់សូវនៅផ្ទះគាត់មានប្រពន្ធច្រើនដែរចឹងគាត់អត់សូវនៅផ្ទះទេ ប៉ុន្តែគាត់ប្រចណ្ឌច្រើនហើយចូលចិត្តធ្វើបាបម្តាយ

ហើយនៅពេលដែលមានបញ្ហាឈ្លោះគ្នាគាត់តែងតែយកញ៉ុមទៅជាមួយដោយសារគាត់ថា
ញ៉ុមហ្នឹងដូចគាត់ កូនគាត់ក្រៅពីហ្នឹងមិនមែនកូនគាត់ទេ
ហើយក្រោយឡើងទៀតញ៉ុមអត់បានទំ
នាក់ទំនងទៀតដោយសារម្ដាយញ៉ុមគាត់ទ្រាំនឹងការរស់នៅជាមួយគាត់អត់បានដោយសារ
គា
ត់អត់បានមើលថែហើយធ្វើបាបម្ដាយរបស់ខ្ញុំទៀតដោយការវ៉ាយដំច្រំធាក់សឹងតែរាល់ថ្ងៃចឹ
ង ម្ដាយខ្ញុំបានសំរេចចិត្តចាកចេញពីគាត់តាំងពីខ្ញុំនៅតូចៗ?

កៈប្រហែលជាអាយុប៉ុន្មានដែរដែលបងចាកចេញពីប៉ារបស់បង?

ខៈប្រហែលជាអាយុ១១ឆ្នាំ។

កៈចឹងវាចូលប្រហែលជាប៉ុន្មានហើយ?

ខៈចូលជិតអើ!!!

កៈ២០ឆ្នាំជាងហើយបងអី?

ខៈហ្នឹងហើយចូលជិត២០ឆ្នាំជាងហើយ។

កៈចាំហ្នឹងហើយ។ចឹងបងសំរាប់ជីតា ជីដូនជីតាខាងម្ដាយរបស់បងវិញតើគាត់ឈ្មោះ
អើជីតា ហាមុនថាជីតាឈ្មោះអ្វីដែរ?

ខៈជីតាខាងណា?

កៈខាងម្ដាយ!!

ខៈខាងម្ដាយ?

កៈចាំ!!

ខៈគាត់ឈ្មោះអើទិត្យ ប៉ុស។

កៈហ្នឹងហើយ។

ខៈហើយគាត់បានទទួលមរណភាពមុនប៉ុល ពតទៅទៀត។

កៈហើយដឹងថាគាត់កើតនៅក្នុងថ្ងៃខែឆ្នាំណាអត់?

ខៈនៅក្នុងនេះគេដាក់ឆ្នាំ១៩១៩។

ក៖អូយ!!យូរណាស់ហើយបងណោះ??

ខ៖បាទ!!

ក៖ហើយគាត់កើតនៅថ្ងៃ។ទីខែឥវ៉ាន់គេមានបា នប្រាប់ទេ?

ខ៖គេអត់មានបានប្រាប់ផងតែឆ្នាំ។

ក៖ចាំចឹងតើគាត់មានទីកន្លែងកំណើតនៅក្នុងភូមិឃុំអីគេដែរបង?

ខ៖គាត់កើតនៅភូមិស្ទឹងជ្រៅ ឃុំចាក់អង្រែ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។និយាយអោយ ចំគាត់កើតនៅអើភូមិស្ទឹងជ្រៅ ពីមុនគេដាក់ឃុំចាក់អង្រែ ឥលូវគេដាក់ឃុំដើមមាន។ក៖ចាំ!!ខ៖ តែយើងដាក់ពីមុនទៅ។

ក៖ហ្នឹងហើយ។

ខ៖ភូមិស្ទឹងជ្រៅ ឃុំចាក់អង្រែ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

ក៖ចាំដូចជាបងកើតអត់ទាន់គាត់ណាមែនទេ?

ខ៖បាទបាទ!!!

ក៖ចឹងបងដែលឮអ្វីខ្លះដូចជាថាតើម្តាយរបស់បងគាត់ប្រាប់បងម៉េចខ្លះអំពីជីតារបស់បងគាត់ ជាមនុស្សម៉េចដែរ?

ខ៖គាត់ប្រាប់ថានិយាយពីជីតារបស់ខ្ញុំគឺគាត់ជាមនុស្សល្អ ពីដើមឡើយគាត់ក៏ជាស្មៀនឃុំមួយ ដែរ គាត់មានមុខដំណែងខ្ពស់ដែរនៅក្នុងនៅក្នុងភូមិហ្នឹងគឺគាត់មានមុខមានមាត់ណាស់ហើយ ហើយតារបស់ខ្ញុំគាត់ចូលចិត្តចិញ្ចឹមក្របី ចិញ្ចឹមចៅ ហើយចិញ្ចឹមកូនចឹង អ្នកស្រុកភូមិក៏ស្រលាញ់គាត់ដែរ។

ក៖ចាំគាត់គឺជាមនុស្សល្អ ។ចឹងសំរាប់យាយរបស់បងវិញម្តងតើឈ្មោះអីគេដែរខាងម្តាយ?

ខ៖យាយខ្ញុំឈ្មោះ អ៊ូ នួន។

ក៖ហ្នឹងហើយតើគាត់កើតនៅក្នុងថ្ងៃខែឆ្នាំណាដែរបង?

ខ៖គាត់កើតនៅក្នុងថ្ងៃខែ ១៩២១។គាត់បានទទួលមរណភាពហើយ ថ្ងៃអត់បានចាំទេ។ថ្ងៃដែ

លគាត់កើតនឹងគឺនៅក្នុងឆ្នាំ១៩២១គាត់កើតនៅភូមិខាងលើដូចតាញ៉ុមដែរហ្នឹង!!
ហ្នឹងហើយ គាត់ស្រលាញ់គ្នានៅក្នុងភូមិហើយចឹង!!

កៈចាំចឹងឃើញគ្នានៅក្នុងភូមិហ្នឹងហើយបងណោះ?

ខៈប្រហែលចឹងហើយអាណាទៅដឹង។ហើយមួយទៀតតារបស់ខ្ញុំបាទហ្នឹងមិញច្រលំការពិត គាត់កើតថ្ងៃទី១៩១៥ច្រលំ១៩១៩ដោយអក្សរវាស្រដៀងគ្នាហ្នឹងហើយ។

កៈចឹងបងតើបងកើតដូចជាយាយតើបងបានឮអីគេខ្លះពីយាយពីម្ដាយរបស់បងតើយាយជាម នុស្សម៉េចដែរ?

ខៈហ៊ីញ៉ុមម៉ែញ៉ុមអត់សូវនិយាយពីយាយទេ តែដឹងថាយាយជាមនុស្សល្អបានហើយ។

កៈអត់សូវនិយាយហ្នឹងនិយាយថាម៉េចទៅ?

ខៈគាត់អត់និយាយ គាត់អត់ដែលរំលឹកពីយាយម៉ងហ្នឹង
រំលឹកតែពីតាដោយសារតាមានមុខមា ត់ ហ្នឹងហើយ។

កៈហ្ហូដោយសារចឹងបានរំលឹកច្រើនទៅ។

ខៈហ្នឹងហើយកុំអោយខាត។

កៈចឹងចូលដល់ជីដូនជីតាខាងឪពុកវិញម្ដង បងស្គាល់គាត់ទេដល់ពេលបែកគ្នាមកយូរចឹង?

ខៈការពិតតាំងពីរបែកគ្នាមិនទាន់បែកគ្នាពីឪពុកខ្ញុំចឹងគឺខ្ញុំមិនដែលឃើញគាត់តាំងពីរដើមមក ហើយហ្នឹង ចឹងញ៉ុមអត់ដែលសូម្បីតែដឹងបន្តិចញ៉ុមអត់ដឹងផងហ្នឹង!!

កៈតិចក៏អត់ដឹងពីតាយាយដែរ?

ខៈអត់សោះម៉ង សូម្បីតែគ្រួសារខាងគាត់ខាងប្រុសខាងស្រីខាងអីក៏ញ៉ុមអត់ដែលដឹងដែរតែ ធ្លាប់ឃើញអ៊ំបងឪពុកញ៉ុមម្ដងស្រី
បងប្អូនជីដូនមួយរបស់ញ៉ុមតាំងពីតូចមកហ្ហុំតែឥឡូវញ៉ុមអ
ត់ដឹងថាពួកគាត់ទៅណាអស់ហើយទេ។

កៈចាំ!!បាត់ឈឹងម៉ងហោ?

ខៈគេមិនបាត់ទេមកពីញ៉ុមអត់ដែលដឹង គេនៅតែរស់នៅហ្នឹង
តែអ្នកខ្លះក៏ងាប់ដែរហើយក៏មិន ដឹង។

កៈហើយចឹងតើឪពុករបស់បងគាត់នៅរស់តើមែនទេ?

ខៈបើជាតុពិតទៅញ៉ុមអត់ដែលដឹងថាគាត់ម៉េចទេ
គាត់ស្លាប់ឬមួយក៏គាត់រស់ម៉េចអត់ដែលដឹ ងសោះ ញ៉ុមអត់ដែលជួបគាត់សោះ។

កៈបិតប្រវត្តិជិតឈឹងម៉ងហ៎?

ខៈបិតជិតឈឹង។

កៈចឹងពេលបងចាកចេញពីគាត់មកគាត់រស់នៅខេត្តអីគេវិញ?

ខៈគាត់នៅបាត់ដំបង។

កៈនៅបាត់ដំបង!!!ស្រុកមោងឬស្សីឬក៏ម៉េច?

ខៈញ៉ុមដឹងតែនៅបាត់ដំបង ព្រោះអីញ៉ុមនៅទូចៗ ចឹងញ៉ុមអត់ដឹងមោងមាំងអីណាទេ!!!

កៈហ្នឹងហើយ ចឹងបងតើបងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈខ្ញុំមានបងប្អូនប្រុស៣នាក់បូកទាំងញ៉ុមហើយមាន៣នាក់ហើយអត់មានបងស្រីប្អូនស្រីទេ សុទ្ធតែប្រុស។

កៈហើយបងជាកូនទីប៉ុន្មានដែរ?

ខៈញ៉ុមជាកូនទី២។

កៈហើយបងប្រុសហើយនឹងប្អូនប្រុសរបស់បងគាត់ឈ្មោះអីគេដែរ?

ខៈគាត់ឈ្មោះ សួន សុខាហើយនឹងឈ្មោះសួន សុខន។

កៈចាំចឹងឈ្មោះសុទ្ធតែស្រដៀងៗគ្នាម៉ង!!!

ខៈបាទកុំអោយពិបាកហៅ!!

កៈចាំឥឡូវពួកគាត់នៅឯណាវិញបង?

ខៈឥឡូវគាត់នៅផ្ទះជាមួយគ្នា។

កៈនៅរួមគ្នានៅស្ទឹងជ្រៅហ្នឹងទាំងអស់គ្នាហេ?

ខៈហ្នឹងហើយប្រមូលមកនៅហ្នឹងទាំងអស់។

កៈចឹងទីកំនើតបងបច្ចុប្បន្នគេហៅអីគេវិញ?

ខ៖គេហៅភូមិស្នឹងជ្រៅ ឃុំដើមមៀន ស្រុកតាខ្មៅ ខេត្តកណ្តាល។

ក៖ចឹងពីមុនមកគេហៅផ្សេង។

ខ៖គេហៅឃុំចាក់អង្រែ។

ក៖ហ្នឹងហើយ។

ខ៖ឥលូវគេដូរហ្នឹងហើយ។

ក៖ពីមុនហ្នឹងគេហៅចាក់អង្រែដែរ?

ខ៖ហ្នឹងហើយហ្នឹងត្រកូលចាក់អង្រែ។

ក៖ចឹងបងចូលដល់ការសិក្សារបស់បងសុខុមវិញ តើបងរៀនបានថា្នក់ទីប៉ុន្មានដែរ?

ខ៖ញុំអើរៀនបានថ្នាក់ទី១២ហើយអើបានរៀននៅសកលវិទ្យាល័យ២ឆ្នាំ។

ក៖ចាំ!!

ខ៖ហើយ បន្ទាប់មកទៀតញុំអត់បានរៀនអស់បន្តទៅទៀតទេ។

ក៖តែត្រឹមសកលវិទ្យាល័យ។

ខ៖ញុំរៀនសកលវិទ្យាល័យ២ឆ្នាំទេហើយញុំនឹងថ្ងៃអនាគតញុំនឹងបន្តរៀនផ្នែកអីមួយ ដើម្បីមាន បរិញ្ញបត្រ័នឹងគេ  កុំអោយខ្មាស់គេ។

ក៖ចឹងសព្វថ្ងៃបងនៅរៀននៅសកលវិទ្យាល័យដែរឬទេ?

ខ៖អត់ទេញុំអត់រៀនទេ។

ក៖ចឹងបង បងរៀនបឋមសិក្សាបងរៀនសាលាឈ្មោះអីដែរ?

ខ៖ញុំរៀននៅបឋមសិក្សាក្រពើហាជិតផ្ទះ។

ក៖ចាចុះដល់ពេលចូលដល់អនុវិទ្យាល័យ?

ខ៖សេរីភាពហើយនឹងវិទ្យាល័យហ៊ុន សែន។

ក៖វិទ្យាល័យហ៊ុន សែន តាខ្មៅហ្នឹង?

ខៈបាទ
!!ពីមុនសេរីភាពមានត្រឹមតែអនុវិទ្យាល័យទេបើយើងចង់រៀនដល់វិទ្យាលយ័ដល់ទៅ
រៀនដល់ហ៊ុន សែន។

កៈហ្ហ៎!!!

ខៈដល់ឥឡូវគេមានទាំងវិទ្យាល័យនឹងអនុវិទ្យាល័យនៅសេរីភា ព បាទ!!!

កៈចាំ!!ចុះសំរាប់សកលវិទ្យាល័យដែលបងរៀនបាន២ឆ្នាំនៅសាលាអីគេវិញ?

ខៈពហុបច្ចេកទេសជាតិកម្ពុជាហើយកាត់ថា ស៊ី អិន អ័រ ភី!!!ណូណូ អិន ស៊ី អាយ ភី បាទៗ
ចង់ភ្លេច។

កៈហ្នឹងហើយ ចឹងបើសិនជាត្រូវបញ្ចប់៤ឆ្នាំមែនទេបង?

ខៈបាទបើចប់ ចប់យូរណាស់ហើយ ៤ឆ្នាំបាទ។

កៈតែបងរៀនបានតែ២ឆ្នាំ?

ខៈបាទ អត់លុយបាទ។

កៈតើបងរៀនយកផ្នែកអីគេដែរ?

ខៈញ៉ុមរៀនយកផ្នែកវិស្វករសំណង់។

កៈហ៎ូ!!ឡូយមែនទែន។

ចៈឡូយស្អីរៀនអត់ចប់ផងហ្នឹង។

កៈតែបងមាននៅចាំខ្លះៗពីមេរៀននៅសាលាហ្នឹងទេ?

ខៈមានអីចាំខ្លះតើ!!

កៈហើយបើយកទៅធ្វើការធ្វើកើតទេ?

ខៈធ្វើមិនកើត ដោយសារគេចង់អោយយើងរៀនចប់
គន្ធាស្សូរចឹងបើរៀនអត់ចប់ផងម៉េចធ្វើកើ ត។

កៈអត់ទេលោបងឯងធ្វើបានដូចជារៀនបានខ្លះៗចឹងអាចចេះទៅដល់ពេលទៅអនុវត្តទៅវា
ចាំ ចេះចឹងទៅណាស់!!

ខ៖បើសិនយើងរៀនហើយយើងយកទៅអនុវត្តយើងប្រហែលជាអាចចេះវិញហ្នឹងហើយ ។

ក៖ ចាំ!!

ខ៖នឹងការងារបង្រៀនមនុស្សតើមានអី!!

ក៖ហ្នឹងហើយ។

ខ៖ញ៉ុមឆ្លាតស្រាប់ហើយដឹងតែចេះវិញហើយ!!!

ក៖ច្បាស់ហើយបងខុមឆ្លាតសឹងអីហើយ!!

ខ៖អរគុណ អរគុណ!!

ក៖ចឹងបងសុខុមសំរាប់សព្វថ្ងៃបងប្រកបរបរអីចិញ្ចឹមជីវិតដែរ?

ខ៖សំរាប់ខ្ញុំគឺខ្ញុំជាអ្នកមគ្គុទេស។

ក៖ទេសចរណ៍ហ្នឹង?

ខ៖បាទមគ្គុទេសទេសចរណ៍ហ្នឹង!!គឺថាញ៉ុមនាំភ្ញៀវដើរកំសាន្តនៅប្រទេសកម្ពុជាហ្នឹង។ក៖ចាំ!!

ខ៖ដោយគិតលុយពីពួកគាត់។

ក៖ចាំចឹងរកកំរៃតាមរយៈការនាំភ្ញៀវដើរកំសាន្តហ្នឹងបងណោះ?

ខ៖បាទ!!

ក៖ចឹងបងដូចជាធ្លាប់បាននាំភ្ញៀវទេសចរណ៍ទៅដល់ខេត្តណាខ្លះបង?

ខ៖ញ៉ុមស្ទើរទាំងគ្រប់ខេត្តហើយ តាំងពីកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពត កំពង់សោ ម និយាយអោយចំស្ទើរសឹងតែគ្រប់ខេត្តហើយ។

ក៖ចាំចឹងបងរបៀបដែលបងនាំភ្ញៀវដើរហ្នឹងវាមានលក្ខណៈម៉េចដែរ?របៀបនាំភ្ញៀវដើរហ្នឹង មធ្យោបាយធ្វើដំនើរស្អីហើយនឹងប្រាប់គេរបៀបម៉េចទៅ ស្គាល់ពីប្រទេសកម្ពុជាយើង?

ខ៖ការពិតទៅពួកខ្ញុំនឹងគេហៅថា Guide adventure !!adventure ហ្នឹងច្រើនតែពួកញ៉ុមហ្នឹងច្រើន តែប្រើកំលាំងពលកម្មជាងការនិយាយ ចឹងនិយាយខ្លីអោយស្រួលស្តាប់ទៅញ៉ុមនាំភ្ញៀវជិះកង់ ដើរកំសាន្តនៅស្រុកខ្មែរ!!

ក៖ចាំ!!

ខ៖ចឹងទៅដល់កន្លែងណាដែលយើងគួរតែរៀបរាប់ទៅ យើង រៀបរាប់ទៅ
ជាប្រវត្តិខ្លះៗនៅប្រទេសកម្ពុជាអំពីភោគផលដំណាំដែលយើងដាំហ្នឹងម៉េចម៉ាចឹង
ទៅ!!ហើយអំពីប្រជាជនតើគេរស់នៅមានបញ្ហាអី ហើយការរស់នៅយ៉ាងម៉េច។

ក៖ចាំ!!

ខ៖ហ្នឹង ហើយហើយនិយាយអំពីសាសនាខ្លះៗ ទាក់ទងនឹងសាសនាព្រាហ្ម
សាសនាព្រះពុទ្ធ សាសនា អីហ្នឹងដែលយើងយល់ហ្នឹងយើងពន្យល់ប្រាប់ភ្ញៀវទៅ
យើងមិនបាច់រ៉ៃរ៉ាប់ច្រើនដូចអើ ដូចហ្គាយដែលនៅសៀមរាបទេ
គឺគេទាមទារអោយពួកគាត់ហ្នឹងមានគេហៅថាមានភាពច្បា
ស់លាស់ដែលពួកញ៉ុមក៏មានភាពច្បាស់លាស់ដែរប៉ុន្តែមិនដឹងច្រើនដូចជាពួកគាត់ទេ!!សំ
រាប់
ពួកគាត់គឺពួកគាត់មានគ្រូបង្ហាត់បង្រៀនអីបន្ថែមទៀតណាស់!!ហើយពួកញ៉ុមគឺរៀនខ្លួនឯ
ង ហើយរៀនពីសៀវភៅហើយ រៀនអំពីអើបទពីសោធន៍ផ្សេងៗទៀត។

ក៖ចាំចឹងញ៉ុមសុំដូចជាអោយបងនិយាយមួយពីរឿងដូចជាទៅលេងឧដុង្គមួយចុះ
តើបងអាច
រៀបរាប់ប្រាប់ភ្ញៀវថានៅឧដុង្គគេធ្វើអីគេខ្លះបងអាចរៀបរាប់ប្រាប់បន្តិចមក!!ពីបទពិសោធ
ន៍ បង?

ខ៖កាលពីជំនាន់បុរាណទៅគឺនៅក្នុងសតវត្សទី១៥គឺយើងបានគឺរាជធានីនៅក្នុងប្រទេសក
ម្ពុ ជាបានផ្លាស់ប្តូរច្រើនណាស់!! យើងផ្លាស់ប្តូរពីរាជធានីអង្គរមកលង្វែក លង្វែរមកឧដុង្គ
ឧដុង្គ ចតុមុខ អាសុំទោស ចតុមុខមកឧដុង្គ ឧដុង្គទៅចតុមុខវិញចឹងអី
ដោយសារយើងមានបញ្ហា ច្រើនជាមួយប្រទេសសៀម
កាលជំនាន់ហ្នឹងយើងមានបញ្ហាច្រើនជាមួយប្រទេសសៀម ហើ
យបញ្ហាមួយទៀតនោះគឺគ្រោះធម្មជាតិជាមូលហេតុមួយដែលស្តេចយើងហ្នឹងតែងតែផ្លាស់
ប្តូរ ទីលំនៅដើម្បីអោយប្រជាពលរដ្ឋហ្នឹងមានភាពងាយស្រួលរួមទាំងស្តេចផង
គេចផុតពីអាគេច ផុតពីគ្រោះទុរភិក្ស គេចផុតពីសង្គ្រាមរវាងថៃ។

ក៖ចាំចឹងបងសំរាប់កន្លែងដែលបងជូនភ្ញៀវទៅទស្សនាហ្នឹងកន្លែងមួយណាដែលបងចូលចិ
ត្ត ខ្លាំងជាងគេបំផុតហើយចង់តែងតែនាំភ្ញៀវទៅជាងគេ ?

ខ៖បើនិយាយទៅសំរាប់ញ៉ុមផ្ទាល់ញ៉ុមចូលចិត្តនៅតាមជនបទ វាលស្រែអីញ៉ុមចូលចិត្តរស់
នៅអើទេសភាព ជាមួយទេសភាព ព្រៃព្រឹក្សាលក្ខ័តារល្លិហ្នឹង

ញ៉ុមចូលចិត្តដែរគ្រាន់តែថាយើ ងបង្ហាញភ្ញៀវអំពីអ្វីៗដែលគាត់មកស្រុកខ្មែរហ្នឹង
ដែលគាត់ចង់ដឹងជាពិសេសប្រាង្គប្រាសាទ អង្គរវត្តហ្នឹង
ដែលជាបេតិកភណ្ឌពិភពលោករបស់ខ្មែរយើងហ្នឹងពួកគាត់គួរតែទៅទស្សនាអំពី អរិយធម៌
វប្បធម៌និងភាពដ៏អស្ចារ្យដែលដូនតាយើងដែលជាប្រជាជនខ្មែរហ្នឹងហើយនឹងស្ដេច
ពីជំនាន់បុរាណហ្នឹងដែលគាត់សាងសង់នូវប្រាសាទអង្គរវត្តដោយមិនបានប្រើស៊ីម៉ង់ន៍អីទេ
បា ទគឺគាត់ប្រើដោយបច្ចេកទេសហ្នឹង អត់ដឹងថាបច្ចេកទេសអីទេ
ពួកគាត់ស្ដេចពីជំនាន់បុរាណ ស្ដេចឆ្លាតៗណាស់!!។

ក៖ចាំ!!

ខ៖មិនមែនដូចពួកឥលូវទេ។

ក៖ចឹងបងឯងពេលទៅប្រាប់ភ្ញៀវ
អត់ទេឥឡូវដោយសារនៅក្នុងប្រទេសកម្ពុជាយើងអ្វីដែល
ល្បីល្បាញជាងគេគឺទីក្រុងសៀមរាបហ្នឹងហើយនៅប្រាសាទអង្គរវត្តហ្នឹង
ចឹងបងប្រាប់ភ្ញៀវត្រួ តៗខ្លះៗអំពីប្រាសាទអង្គរហ្នឹងរបៀបម៉េចដែរបងអាចប្រាប់បន្តិចមក
ដោយសារជាហ្គាយចឹង ដឹងច្រើន!!!

ខ៖ដូចញ៉ុមបានប្រាប់ពីខាងលើរួចហើយ
ញ៉ុមមិនមែនជាហ្គាយមួយដែលច្បាស់លាស់ប៉ុន្មាន
ទេប៉ុន្តែញ៉ុមរៀនដូចគ្នាហើយសំរាប់ពួកខ្ញុំគឺគ្រាន់តែជាGuide adventure
ទេប៉ុន្តែបានដឹងខ្លះៗអំ ពីប្រាសាទអង្គរវត្តហ្នឹង
អង្គរវត្តហ្នឹងគឺសាងសង់នៅសតវត្សទី១២គឺដោយព្រះបាទសុរិយវរ្ម័ទី
២សំរាប់ឧទ្ទិសដល់ព្រហ្មញ្ញណសាសនានឹងព្រះពុទ្ធសាសនាបាទហើយគឺកន្លែងហ្នឹងអស្ចា
រ្យ មែនទែនបើសិនជាយើងបានទៅទស្សនាប្រៀបដូចជាយើងបានទៅនគរឋានសួគ៌ចឹង
ប្រៀបដូ ចាជានគរឋានសួគ៌មិនមែនសប្បាយអស្ចារ្យប៉ុន្តែគ្រាន់វាអស្ចារ្យ
យើងមើលទៅគឺអស្ចារ្យដោយ
សារមនុស្សមួយចំនួនបាននិយាយថាប្រាង្គប្រាសាទអង្គរវត្តគឺជាឋានសួគ៌នៅលើផ្ទៃដី
បាទ!!

ក៖ហ្នឹងហើយដោយសារវាអស្ចារ្យពេកមែន?

ខ៖បាទគឺវាអស្ចារ្យ។

ក៖ដោយសារសាងសង់ឡើងអត់ប្រើស៊ីម៉ង់ន៍មែនទេបង?

ខ៖បាទហើយយើងឃើញថាថ្មធំៗណាស់
ហើយជំនាន់នោះគឺឃើប្រើដំរីដើម្បីសាងសង់ហើយ នឹងគឺប្រើមនុស្ស
មនុស្សកើនៗនឹងចាប់មនុស្សជាឈ្លើយសឹកដើម្បីយកទៅធ្វើ។

ក៖ចាំ!!

ខ៖ប្រា
ង្គប្រាសាទស្តេចបានជីកបារាយណ៍ដើម្បីជួយធ្វើជំនាំភោគផលដើម្បីជួយស្តេចបានសង់ទំនប់ ទឹកពទ្ធ័ជុំវិញ
កស្សិណទឹកពន្ធ័ជុំវិញប្រាង្គប្រាសាទអង្គរវត្តអោយអង្គរវិត្តអាចបិតថេរបានយូរ។

ក៖ហ្នឹងហើយ។

ខ៖ចឹងនៅប្រាសាទដ៏មហិមានេះគឺអើបានស្តេចជាច្រើនបានសាងសង់នៅនេះខ្ញុំលើកយកតែ
ស្តេចដែលគាត់មានអំណាចដ៏ខ្លាំងក្លាដូចជាព្រះបាទជ័យវរ្ម័ន៍ទី៧គឺគាត់បានសាងសង់ប្រាសាទជាច្រើនតែខ្ញុំលើកយកតែប្រាសាទ២ទេដោយសារប្រាសាទនេះល្បីមែនទែន!!សូម្បីតែ អែន ជីលីណាជូលី ក៏គាត់បានមកថតខ្សែភាពយន្តនៅប្រទេសកម្ពុជាយើងដែរ
គេហៅថាប្រាសាទ តាព្រហ្មនិងប្រាសាទបាយ័ន
ចឹងប្រាសាទនេះគឺដូចគ្នាគឺសាងសង់ឡើងចុងសតវត្សទី១២
ហើយបញ្ចប់នៅចុងសតវត្សទី១៣ព្រះបាទជ័យវរ្ម័ន៍ទី៧គឺទ្រង់ឧទ្ទិសថ្វាយដល់ព្រះពុទ្ធសាសនាហើយនៅក្នុងនោះក៏មានអើសាសនាព្រហ្មញ្ញផងដែរចឹងគឺជាមួយគ្នាគឺនៅក្នុងប្រាសាទអង្គរ
វត្តមានទាំងសាសនាព្រហ្មញ្ញនឹងសាសនាព្រះពុទ្ធនៅជាមួយគ្នាចឹងគេនៅតែគោរពថ្វាយបង្គំចឹ ងហើយអើព្រះបាទជ័យវរ្ម័ន៍ទី៧គឺជាស្តេចមួយក៏អស្ចារ្យដែលគាត់បានវ៉ៃឈ្នះថ្វាបានពង្រីកទឹ
កដីធំល្វឹងល្វើយរហូតដល់ព្រំប្រទល់ប្រទេសចិនប៉ុន្តែដោយសារបន្តមកទៀតដោយសារសង្គ្រា
មផ្ទៃក្នុងរវាងបងប្អូនធ្វើអោយប្រទេសកម្ពុជាបានបាក់បែកគ្នាម្តងបន្តិចៗរហូតមកដល់សព្វថ្ងៃ នេះជាមូលហេតុមួយដែលប្រទេសកម្ពុជាមានរហូតទូចទៅៗ។

ក៖ចាំចឹងបងនៅតំបន់អង្គរតើប្រាសាទណាដែលបងស្គាល់ខ្លះតើបងអាចរៀបរាប់ឈ្មោះប្រា សាទដែលបងស្គាល់ហាំ?

ខ៖បាទញ៉ុមស្គាល់ប្រាសាទដូចជាប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន ប្រាសាទតាព្រហ្ម ប្រាសា ទលលៃ ប្រាសាទព្រះកែវ ប្រាសាទព្រះខ័ន ប្រាសាទប្រែរូប ប្រាសាទបាខែង

ប្រាសាទបាគង ប្រាសាទទីលានជល់ដំរី បាទនិងប្រាសាទជាច្រើនទៀតបាទ ញ៉ុមរៀបរាប់អត់អស់ទេច្រើនពេ ក។

កៈ
ចាំចឹងបងសំរាប់អារម្មណ៍របស់បងវិញតើក្នុងនាមបងជាកូនខ្មែរហើយដូនតាបន្សល់ទុកនូវប្រាសាទបុរាណជាច្រើនតើបងមានអារម្មណ៍យ៉ាងម៉េចដែរហើយចង់និយាយទៅកាន់ពិភពលោកថាយ៉ាងម៉េចដែរសំរាប់ប្រទេសខ្មែរ?

ខៈបាទសំរាប់ញ៉ុមញ៉ុមដឹងថាប្រាសាទ គឺមាន
សារៈសំខាន់ណាស់សំរាប់ប្រជាជនខ្មែរដោយ
សារយើងទទួលបានថវិកាចូលជាតិហើយនឹងប្រជាពលរដ្ឋអាចចិញ្ចឹមជីវិតបានទៅតាមរយៈ ភ្ញៀវទេសចរណ៍
ចឹងញ៉ុមសូមអោយពិភពលោកឬក៏រាជរដ្ឋាភិបាលជួយថែរក្សាប្រាសាទអោយ
បានគង់វង្សមិនថា
មិនថាក្បាច់ក្បូរចនាមិនថាទីតាំងឬមិនថាអីទេគឺយើងត្រូវរក្សាវាអោយបាន
ល្អហើយសំរាប់អើយយើងឃើញថាវាមានការឈ្លានពានច្រើនពីពួកបរទេស
ញ៉ុមសង្ឃឹមថា ប្រាសាទនេះនឹងនៅតែជាប្រទេសកម្ពុជា
ប្រទេសកម្ពុជានៅតែជាប្រទេសកម្ពុជាមិនអាចផ្លាស់ ប្តូរបានទេ!!!

កៈចាំហ្នឹងហើយចឹងបងសំរាប់បងខុមវិញចូលដល់ចំនង់ចំនូលចិត្តរបស់បងចូលចិត្តពិសារម្ហូប អីគេដែរបងសុខុម?

ខៈញ៉ុមនិយាយទៅញ៉ុមកើតនៅប្រទេសកម្ពុជាចូលចិត្តញ៉ាំម្ហូបខ្មែរ។

កៈហ្នឹងហើយម្ហូបខ្មែរដែលពិសេសបំផុតដែលបងខុមចូលចិត្តញ៉ាំ?

ខៈភាគច្រើនញ៉ុមចូលចិត្តញ៉ាំឆាក្តៅ ឆាក្តៅសាច់មាន់ ឆាក្តៅកង្កែបហ្នឹង
ហើយស្ងោរជ្រក់មាន់ ហើយឆាស្ងោរអីហ្នឹងបាទ។

កៈចាំចឹងបងចូលចិត្តរបៀបសាច់ៗណោះបង?

ខៈអើការពិតញ៉ុមចូលចិត្តបន្លែច្រើនដែរ។

កៈចាំ!!!

ខៈបន្លែៗញ៉ុមចូលចិត្តសាច់និយាយចឹងបាទ គឺចំរុះ។

កៈចឹងតើបងសុខុមចេះធ្វើម្ហូបហ្នឹងទេ?

ខះញ៉ុមថីមិនចេះតែញ៉ុមអត់ធ្លាប់ធ្វើផង។

កះហើយអ្នកណាគេបង្រៀនបងឯងវិញ?

ខះនៅពីទូចញ៉ុមជាអ្នកធ្វើម្ហូបនៅផ្ទះដោយសារបងខ្ញុំម្តាយបងខ្ញុំអីគាត់ចេញទៅធ្វើការអស់ទៅ ខ្ញុំជាអ្នកធ្វើម្ហូបនៅផ្ទះ ចឹងញ៉ុមចេះ។

កះចាំចឹងបង
បងដូចមានចាំអីខ្លះពីតូចមកដល់ធំមកហ្នឹងតើបងដូចជាចាំអីគេជាងគេបំផុតនៅក្នុងជីវិតរបស់បង?

ខះអារម្មណ៍អីគេចង់និយាយថាម៉េច?

កះដូចជាជីវិតរបស់បងដែលសប្បាយជាងគេបំផុតហើយឬក៏កើតទុក្ខជាងគេចឹងហាំ??ឥឡូវ សប្បាយមុនបងឯងចាំអីគេជាងគេ?

ខះបាទតាំងពីតូចរហូតដល់ធំអ្វីដែលសប្បាយជាងគេញ៉ុមមានម្តាយដ៏ល្អគាត់តែងតែមើលថៃ ញ៉ុមអស់ពេញមួយជីវិតសូម្បីតែឥឡូវគាត់នៅតែបារម្ភពីពួកខ្ញុំដែរ
គាត់ស្រលាញ់កូនណាស់។

កះចឹងសប្បាយថាមានម្តាយដែលល្អ។ចុះពិបាកជាគេដែលចង់ចាំបំផុតហាំ?

ខះពិបាកបំផុតគឺអើខូចចិត្តbroken heart ។

កះខូចចិត្តរឿងអី?

ខះbroken heart ទាក់ទងនឹងស្នេហានឹងហើយ !!ចាំបាច់បញ្ជាក់។

កះអ៎ូបាត់បង់ស្នេហាធ្វើអោយពិបាកចិត្តមែនទែនបងណោះ?

ខះហ៊ឺៗ!!!

កះឈឺកំរិត វី អាយ ភី!!!

ខះ វី អាយ ភី ។

កះអូខេ !!ចឹងបងតើបទចំរៀងបងចូលចិត្តស្តាប់បទចំរៀងដែរអត់?

ខះហ្នឹងហើយញ៉ុមចូលចិត្តច្រៀងញ៉ុមចូលចិត្តស្តាប់បទចំរៀង
ជាពិសេសញ៉ុមចូលចិត្តខារ៉ាអូ ខេពេលមានលុយ ។

កៈហើយតើបងចូលចិត្តបទរបៀបម៉េចដែរ?

ខៈរ៉ូមែនទិក!!!

កៈរ៉ូមែនទិកហ៎??បងចេះច្រៀងតើមែនទេ?

ខៈចេះតើ!!

កៈហ្នឹងហើយ
!!ចឹងតើមួយណាដែលបងខុមចូលចិត្តខ្លាំងជាងគេបំផុត?មួយណាបងសុខុម?

ខៈអើការពិតបំផុតហ្នឹងវាត្រូវហើយ
ក៏ប៉ុន្តែបើបំផុតដែលញ៉ុមលើកយកមកទាំងអស់វាសុទ្ធតែ បំផុតហើយ
តែគេចង់អោយយកតែមួយឬក៏ចង់អោយយកច្រើន?

កៈច្រើនក៏បានដែរដោយសារចូលចិត្ត!!!

ខៈបើនិយាយទៅល្បីជាងគេ ព្រាប សុវត្ថិ ចឹងប្រាកដជាចូលចិត្តអ្នកដែលល្បីហើយ ព្រាប
សុវត្ថិ !! ខេមរៈ សេរីមន្តអើឆាយ វីរៈយុទ្ធ ហ្នឹងហើយហ្នឹងសុទ្ធតែជា
អាយដលរបស់ញ៉ុមហើយ ហើយអើអ្នកណាទៀតទេ!!
ហ្នឹងហើយលើកតែ៣ហ្នឹងបានហើយ!!

កៈសំខាន់ជាងគេ??

ខៈការពិតញ៉ុមចូលចិត្តច្រើន ហ្នឹងហើយ ចឹងសំខាន់។

កៈចាំចឹងសំរាប់បងសុខុមចេះលេងឧបករណ៍តន្ត្រីអីអត់?

ខៈចេះព្យាណូតិចតួច
ទៅមិនរួចទេបើគេអោយលេងហ្ន៎!!គ្រាន់តែចុចៗបានដឹងណូតដឹងអី។

កៈអ្ហ៎!!ចឹងមានបងប្អូនណាចេះលេងមួយហ្នឹងទេ?

ខៈដូចជាអត់មានទេ!!

កៈ ហ្នឹងហើយចេះតែបងខុមហ្នឹងតិចតួចមួយ!!

ខៈបាទ!!

កៈចឹងតើបងរៀនព្យាណូហ្នឹងពីអ្នក  ណាគេមកវិញ?

ខៈខ្ញុំរៀនពីអ្នកផ្សាយសាសនា
លោកតាលោកយាយដែលគាត់បានមកបំរើនៅប្រទេសកម្ពុជា ហ្នឹងគាត់បានបង្រៀន
តែជាអកុសលណាស់នៅពេលដែលគាត់បង្រៀនងងុយគេងរហូតចឹង
ញ៉ុមទៅដេកហើយ!!!ជាមូលហេតុដែលចេះបន្តិចបន្តួច។

កៈបើខិតខំជាងហ្នឹងតិចទៀត!!!

ខៈប្រាកដជាចេះច្រើនហើយ!!!

កៈហ្នឹងហើយ។

កៈចឹងនិស្ស័យញ៉ុមហ្នឹងវាអត់មានជាមួយតន្ត្រី អារឿងលេងអោយគេស្តាប់ហ្នឹង!!

កៈចឹងបងសំរាប់ប្រទេសខ្មែរយើង យើងកើតមក យើងអត់ទាន់ជំនាន់៣ឆ្នាំ ៨ខែ
២០ថ្ងៃហ្នឹង ទេគេហៅថាជំនាន់ប៉ុល ពត
!!ចឹងតើបងអាចប្រាប់ញ៉ុមខ្លះៗអំពីអ្វីដែលបងសិក្សាក៏ដូចជាដំនើ
ររឿងដែលម្តាយរបស់បងបាននិយាយប្រាប់ដូចជាតើប្រទេសកម្ពុជាយើងធ្លាក់ទៅក្នុងរបប
ហ្នឹង ម៉េចដែរដូចជាលន់ នល់ ហើយនឹង ប៉ុល ពត បងអាចប្រាប់មក?

ខៈការពិតបើសិននិយាយពីជំនាន់លន់ នល់ !!លន់ នល់
គាត់គឺជាម្នាក់ដែលស្រលាញ់ប្រទេស កម្ពុជាយើង ស្រលាញ់ទឹកដីរបស់គាត់
ចឹងគាត់តែងតែការពារកុំអោយអាជនជាតិបរទេសឈ្លា នពាន
និយាយអោយចំទៅគឺអាជនជាតិយួនហ្នឹងតែម្តង ឈ្លានពាន គឺជំនាន់លន់ នល់ គាត់បា
នបណ្តាញ់ជនជាតិវៀតណាមជាច្រើនត្រលប់ទៅវិញហើយគាត់បានសំលាប់ជនជាតិវៀត
ណា
មជាច្រើនផងដែរដោយសារអី!!គាត់បានទុកឪកាសអោយពួកគេដើម្បីចាកចេញពីប្រទេស
កម្ពុ ជាប៉ុន្តែពួកគេរឹងទទឹង នេះជាមូលហេតុមួយដែល លន់
នល់គាត់ត្រូវតែសំរេចចិត្តដើម្បីសំលា
ប់ជនជាតិយួនដើម្បីអោយព្រមានដើម្បីអោយគេត្រលប់ទៅប្រទេសគេវិញ!!!បាទ
ប៉ុន្តែស្តេច គាត់ខ្លាចបាត់បងអំណាច គាត់
ជាមូលហេតុមួយគាត់បានប្រកាសតាមវិទ្យុអោយដើម្បីអោយ
អស់អ្នកណាដែលស្រលាញ់គាត់សំដែងជាស្តេចធ្វើជាឪពុកម្តាយគឺរត់ចូលទៅព្រៃម៉ាក់គីដើ
ម្បី ប្រមូលទ័ពហ្នឹងមកវ៉ៃដល់លន់ នល់ ដើម្បីអោយមកសំលាប់លន់ នល់ ចោល
ដើម្បីអោយមក កាន់អំណាចវិញ បាទហើយដល់ពេលក្រោយមកទៀតស្តេចហើយនឹងប៉ុល
ពតវាគឺជាបងប្អូន

ថ្ងៃនឹងគ្នាពីមុនគឺគាត់អត់ចូលចិត្តគ្នាទេប៉ុន្តែដោយសារគាត់ចង់បានអំណាច ចង់បានអីៗផ្សេង ៗគឺគាត់សហការណ៍គ្នាដើម្បីកំចាត់សេនាប្រមុខ លន់ នល់ចោល !!។

កៈចា!!!

ខៈហើយក៏គាត់ បានទទួលជ័យជំនះនៅថ្ងៃទី១៧មេសា ១៩៧៥។

កៈចឹងបងពេលជំនាន់ លន់ នល់ បងមានឮថាគេទំលាក់គ្រាប់ទំលាក់អីៗអត់?

ខៈការពិតពេលជំនាន់លន់
នល់អើញ៉ុមអត់សូវដឹងច្បាស់ទេគឺទំលាក់គ្រាប់ហ្នឹងគឺទំលាក់នៅ
អាមេរិចកាំងទំលាក់ហ្នឹងគ្រាប់ហ្នឹងទំលាក់នៅដើម្បីទំលាក់ទៅវៀតណាមទេបាទ
ទំលាក់ទៅ វៀតណាមទេតែវៀតណាមនៅលើទឹកដីកម្ពុជា។

កៈចឹងគាត់ទម្លាក់ត្រូវប្រជាជនយើងដែរ?

ខៈគិតថាវាអាចគេចមិនផុតទេ!!

កៈចាំ!!ចឹងតើចូលដល់ជំនាន់ ប៉ុល
ពតវិញតើបងអាចរៀបរាប់បានក្បោះក្បាយពីជំនាន់ប៉ុល ពតដែលបងបានឮ?

ខៈការពិតហ្នឹងហើយ
បើសិនញ៉ុមបានឮញ៉ុមបានឮតែបើថាអោយញ៉ុមកើតនៅជំនាន់ហ្នឹងញ៉ុ មសុខចិត្តស្លាប់ហ្ន៎!!
ដោយសារញ៉ុមប្រហែលជាញ៉ុមមិនអាចរស់ដែរដោយសារជំនាន់៣លាន
នាក់ជាគឺត្រូវបានទទួលមរណៈភាព
ដោយសារការអត់ឃ្លានៗការសំលាប់ការធ្វើទារុណកម្មជា
ពិសេសនោះស្លាប់ដោយសារអត់ឃ្លានតែម្តង
បាទដោយសារការអត់ឃ្លានហ្នឹងមធ្យមទេគឺការ បង្ខំអោយធ្វើការពីព្រឹកទល់ព្រលប់
ដោយការទទួលម្ហូបទទួលទានអាហារហ្នឹងគឺតិចតួចបំផុត
មិនអាចនឹងត្រូវហ្នឹងកំលាំងនេះជាមូលហេតុដែលស្លាប់ដោយការធ្វើការហួសកំលាំងហើយ
ការបរិភោគគឺវាតិចបាទ។

កៈចឹងគឺដូចជាម្តាយបងមានប្រាប់បងថាជីវិតរបស់គាត់ម៉េចដែរ?

ខៈអើការពិតគឺគាត់អត់សូវបាននិយាយច្រើនទេប៉ុន្តែគ្រាន់តែគាត់ថាវាជំនាន់របស់គាត់ហ្នឹង
គឺ ពិបាកណាស់
គឺធ្វើការលំបាកមែនទែនគឺអត់មានសិទ្ធសេរីភាពអីដូចបច្ចុប្បន្នកាលទេឥឡូវដ
ល់សេរីភាពពេកទៅយើងវេទនាជាងមុនទៅទៀត!!

ក៖ចាំ!!

ខ៖វេទនាផ្លូវចិត្តតែម្តង!!

ក៖ចឹងបងក្នុងនាមបងជាកូនខ្មែរដើម្បីដូចជាអោយជៀសផុតពីសង្គ្រាមក៏ដូចជាអ្វីដែលមិនល្អ
តើបងជាកូនខ្មែរតើបងត្រូវធ្វើយ៉ាងម៉េចក៏ដូចជាចង់ផ្តាំផ្ញើរទៅអ្នកជំនាន់ក្រោយក៏ដូចជាអ្នកជំ នាន់តើត្រូវធ្វើម៉េចទៅ?

ខ៖បាទបើតាមគំនិតរបស់ខ្ញុំដើម្បីជៀសផុតពីសង្គ្រាមគឺកុំអោយឈ្លានពានពីគ្នារវាងគ្នានិងគ្នា និងយើងអាចឈ្នះផុតពីសង្គ្រាមហើយបាទ!!!!

ក៖ចាំហ្នឹងហើយល្អមែនទែនបងត្រឹមត្រូវបំផុត!!អូខេសំរាប់ចូលដល់ជីវិតអាពាហ៍ពិពាហ៍បងខុ មរៀបការហើយនៅបងសុខុម?

ខ៖ខ្ញុំអត់មានអ្នកណាយកទេបាទ!!

ក៖ហើយចឹងចឹបានបងឯងនិយាយចឹង?

ខ៖ញ៉ុមសម្រស់អត់សូវស្អាត តាមយថកម្មទៅ!!!

ក៖ហើយបងចុះសំរាប់គោលដៅសំលាប់បងវិញតើបងចង់បានភរិយាម៉េចដែរ?

ខ៖សំរាប់ញ៉ុមគាត់!!

ក៖អត្តចរិកឬក៏ម៉េចចឹងហាំ?

ខ៖ញ៉ុមអើសំរាប់អត្តចរិករបស់មនុស្សយើងអាចកែបានតែសំរាប់ញ៉ុម
ញ៉ុមអត់ដឹងចិត្តរបស់ញ៉ុ
មស្រលាញ់ញ៉ុមស្រលាញ់ហើយញ៉ុមអត់ខ្វល់ពីអត្តចរិកគាត់ម៉េចទេ អាហ្នឹងចិត្តរបស់ខ្ញុំ!!

ក៖តែស្រលាញ់ស្រលាញ់ហើយទោះម៉េចក៏ដោយ?

ខ៖អើយើងចិត្តរបស់ញ៉ុមស្រលាញ់
ស្រលាញ់ហើយប៉ុន្តែទោះយ៉ាងម៉េចក៏ដោយក៏នៅតែស្រ លាញ់ទេប៉ុន្តែយើងមើលដែរ
ប៉ុន្តែបើចិត្តញ៉ុមស្រលាញ់គឺញ៉ុមស្រលាញ់។

ក៖អូខេ !!គាត់ត្រូវជានារីយ៉ាងម៉េចៗបងអត់រើសប៉ុន្មានដែរ?

ខ៖ញ៉ុមគិតថាញ៉ុមរើស ទីមួយគាត់ឆ្លាត !!ញ៉ុមចូលចិត្តអ្នកឆ្លាត ព្រោះញ៉ុមឆ្លាតដែរ !ញ៉ុមចូល ចិត្តអ្នកឆ្លាត បាទគាត់មានចរិកឆ្លាត ពាក្យថាឆ្លាតមួយម៉ាត់គឺគ្រប់គ្រាន់ហើយសំរាប់ញ៉ុមបាទ!!

ក៖ចឹងបងសំរាប់បងតើអនាគតរបស់បងក្ដីស្រម៉ៃចឹងហា៎!!តើបងចង់មានកូនប្រុសស្រីប៉ុន្មាន នាក់?

ខ៖អត់ដែលគិតពីបញ្ហាហ្នឹងផង!!

ក៖អត់មានគំរោងការអីទេហោ?

ខ៖
អើញ៉ុម!!បើនិយាយពីមនុស្សទាំងអស់គឺគេមិនគិតទេលើកលែងតែគេមានភរិយាឬក៏មាន ស្វាមីហើយគេនឹងចាប់ផ្ដើមគិតគូរហើយ!!

ក៖ចា៎!!

ខ៖ហើយសំរាប់ញ៉ុម ញ៉ុមអត់ទាន់មានអ្នក ណាគេផងញ៉ុមពិបាកញ៉ុមគិតណាស់!!!

ក៖ចា៎!!

ខ៖បាទបើមានញ៉ុមនិងគិតថាញ៉ុមគួរតែមានកូនប៉ុ
ន្មានដើម្បីថាអាចកំលាំងរបស់ញ៉ុមទៅរួច បើញ៉ុមយកលើសជំនួនគឺញ៉ុមអត់អាចផ្គត់ផ្គង់ គាត់បានគឺញ៉ុមធ្វើអោយគាត់ពិបាក។

ក៖ចា៎!!ចឹងបងក្ដីស្រម៉ៃរបស់បងនៅពីក្មេងបងមានក្ដីស្រម៉ៃថាធំឡើងបងចង់ធ្វើអីគេ?

ខ៖អូយច្រើនណាស់ប៉ុន្តែទីបំផុតគឺអត់បានដូចបំណង។

ក៖បងចង់ធ្វើអីគេជាងគេ?

ខ៖ដំបូងញ៉ុមចង់ធ្វើ ពីទូចមកញ៉ុមចង់ធ្វើជា គ្រូបង្រៀន មេធាវី!!

ក៖ចា៎!!

ខ៖ទិចណូឡូជី អាយធី ហើយអើ ដឹងស្អីទៀតទេញ៉ុមភ្លេចអស់ហើយ
ហើយឥឡូវញ៉ុមអត់បានធ្វើអ្វីដែលញ៉ុមចង់ធ្វើ។

ក៖ចា៎ចឹងសំរាប់បច្ចុប្បន្នហ្នឹងគោលដៅរបស់បងទៅថ្ងៃអនាគតបងចង់ធ្វើអីគេ?

ខ៖ញ៉ុមចង់ធ្វើអី!!

ក៖អនាគតហាំ?តើបងចង់ក្លាយជាអីគេមួយ?

ខ៖ញ៉ុមចង់ធ្វើជា ញ៉ុមអត់ដឹងថាញ៉ុមចង់ធ្វើអី?ជាជីពឬក៏មុខរបរ?

ក៖ហ្នឹងហើយ។

ខ៖ឥឡូវហ្នឹងញ៉ុមរៀនផ្នែកមគ្គុទេសញ៉ុមគិតថាប្រហែលជាថ្ងៃអនាគតទៅញ៉ុមនឹងធ្វើមគ្គុទេស ទេសចរណ៍។

ក៖ចាំ!

ខ៖ប៉ុន្តែញ៉ុមអត់ដឹងថាទៅថ្ងៃខាងមុខទៀតខ្ញុំនឹងជាប្រធានក្រុមហ៊ុនអីមួយ
ញ៉ុមអត់ដឹងដែរ។

ក៖ហ្នឹងហើយ
ជូនពរអោយបានជោគជ័យធ្វើជាប្រធានក្រុមហ៊ុនហើយហៅញ៉ុមធ្វើជាបុគ្គលិក!

ខ៖ហ្នឹងហើយអត់បញ្ហា!!

ក៖ហ្នឹងហើយ។
ចឹងបងតើដូចជាមនុស្សម្នាក់ៗមានការសិក្សាឬក៏មានកូនទៅចង់អោយកូនសិក្សាហើយមែនទេបង?

ខ៖បាទ!!

ក៖ពេលបងពេលអនាគតទៅដូចជាពេលបងមានកូនបងនឹង
អោយគាត់ទៅសិក្សាទាំងអស់គ្នាអត់?

ខ៖ប្រាកដជាទៅ!!

ក៖ចឹងមូលហេតុអីបានបងចង់អោយកូនបងទៅសិក្សាពេលអនាគតហ្នឹង?

ខ៖ចាំបាច់សួរដែរអីហាំ?

ក៖ហ្នឹងហើយសំរាប់ពេលខ្លះគេអត់ខ្វល់ពីមូលហេតុអីយើងត្រូវតែដឹងពីមូលហេតុចឹងហាំ?

ខ៖មូលហេតុដែលចង់អោយគាត់សិក្សាទី១ចង់អោយគាត់មានវិជ្ជាជីវៈផ្ទាល់ខ្លួន ចំនេះវិជ្ជាចេះ

ដឹងខុសត្រូវហើយនៅពេលរៀនទៅអនាគតគឺគាត់មានវិជ្ជាជីវខ្លួនឯងមានន័យថាគាត់មាន
ប្រក បមុខរបរ ម៉េចម៉ាគាត់អាចចិញ្ចឹមជីវិតខ្លួនឯបាន
គាត់អាចធ្វើអីដោយខ្លួនឯងបានចឹងយើងមិន បាច់បារម្ភ។

កះចាំហ្នឹងហើយ។ចឹងបងតើតំលៃនៃការអប់រំមានអត្ថន័យយ៉ាងណាសំរាប់ជីវិតរបស់បងខុ
ម ជួយបងខុមបញ្ចៀសពីអ្វីខ្លះ?

ខះជីវិតញ៉ុមការអប់រំគឺវាល្អទី១អើនៅពេលដែលយើងរៀនច្រើនយើងយល់ពីសង្គមច្រើន
យើង នឹងព្យាយាម ជៀសផុតពីអំពើអាក្រក់ យើងព្យាយាមធ្វើអំពើល្អជាមួយសង្គមគ្រួសារ
សង្គមប្រ ទេសជាតិ សង្គមផ្សេងៗទៀត។

កះហ្នឹងហើយ
ចឹងតើបងសុខុមតើធ្វើយ៉ាងម៉េចដើម្បីអោយក្រុមគ្រួសាររបស់បងមានសុភមង្គ
លសំរាប់ផែនការទៅថ្ងៃអនាគតក៏ដូចជាបច្ចុប្បន្នរស់នៅជាមួយម្តាយ?

ខះសំរាប់ញ៉ុម ញ៉ុមចង់មានការងារមួយដែលប្រាកដប្រជា
មានប្រាក់ចំណូលសមរម្យដើម្បីស មរម្យញ៉ុមអត់ចង់មានអីច្រើនទេជីវិតរបស់ញ៉ុម
ញ៉ុមចង់បានមានមុខរបរសមរម្យមកហើយញ៉ុ
មអាចដឹកនាំក្រុមគ្រួសារញ៉ុមមកព្រះវិហាររាល់សប្តាហ៍នឹងបំរើការព្រះនេះជាអ្វីដែលញ៉ុមច
ង់ បានហើយមានរថយន្ត យានជំនិះមួយហើយនឹងមានអើដី ដីដែលមានព្រៃព្រឹក្សា
លក្ខ័តាវល្លិ នៅតាមខេត្តណាមួយឬក៏ជិតផ្ទះណាមួយគឺស្កប់ស្កល់នៅក្នុងជីវិតរបស់ខ្ញុំ។

កះចាំចឹងបងតើឆ្លងកាត់ការងារអីគេខ្លះហើយនៅក្នុងជីវិតរបស់បង?

ខះញ៉ុមធ្លាបឆ្លងកាត់ច្រើនដែរ
ញ៉ុមធ្លាប់ធ្វើជាអ្នកផ្សាយសាសនាពេញម៉ោងនៅក្នុងសាសនា
ព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ញ៉ុមធ្លាប់ធ្វើជាអ្នកទទួលភ្ញៀវនៅសណ្ឋានគា
ញ៉ុ មក៏ធ្លាប់ជាដឹកជញ្ជូនឥវ៉ាន់នៅសណ្ឋានគា ហើយញ៉ុមធ្លាប់ធ្វើជាអ្នកអើ
ហ្គាយមគ្គុទេសទេសច រណ៍ បាទ!!

កះចាំចឹងបងដែលធ្លាប់ធ្វើស្រែចំការអត់?

ខះបើនិយាយទៅញ៉ុមជាកូនអ្នកក្របុ៉ន្តែញ៉ុមមិនដែលធ្វើទេ!!!

កះហ្នឹងហើយចឹងបងតើអើបងខុម បងសុខុមរាល់ថ្ងៃរស់នៅក្នុងផ្ទះម៉េចដែរ?

ខះញ៉ុមរស់នៅក្នុងផ្ទះសមរម្យគឺផ្ទះ!!!

កៈផ្ទះបុរាណឬក៏ម៉េចដែរ?

ខៈផ្ទះសម័យ សម័យនេះហើយអាណាទៅនៅផ្ទះបុរាណទៀត!!

កៈលោម៉ូតម៉ាកបុរាណចឹងទៅណាស់!!!

ខៈអុំអត់ទេ!!

កៈផ្ទះបងថ្មឬក៏ឈើ?

ខៈអូតបន្តិចចុះ ថ្ម
ស្រុកខ្មែរអូតមិនកើតទេថ្មហ្នំ!!ហាំនៅស្រុកខ្មែរអូតបានថ្មនៅស្រុកគេអូតមិន បានទេ ។

កៈតើអើដូចជាការសាងសង់ផ្ទះហ្នឹងបងជួលគេឬក៏បងសាងសង់ដោយខ្លួនឯង?

ខៈជួលគេ។

កៈជួលគេហោ?ហ្នឹងហើយ!!តើបង បងប្អូនបងដូនតារបស់បងមកតើមានអ្នកណាគេធ្លាប់ធ្វើស្រែចំការកូរស្ករត្នោត ត្បាញកន្រ្តកត្បាញអីអត់?

ខៈអត់អាលីង!!

កៈអត់មានដែលអ្នកណាគេធ្វើមួយហ្នឹងទេហោ?

ខៈអត់ទេ!!

កៈអត់ដែលដឹងមែន?

ខៈអើនៅជាមួយគ្នារាប់ឆ្នាំហើយប៉ុន្តែពួកគាត់អត់ដែលធ្វើទេ!!

ខៈនិយាយខ្លីអោយស្រួលស្តាប់ទៅ យើងអត់មានដី ដីស្រែ
ចំការអីទេហ្នឹងជាមូលហេតុដែល យើងអត់អាចធ្វើបាន។

កៈចាំចឹងបងសំរាប់ជីវិតរបស់បងសំរាប់ប្រៀបធៀបពីអតីតកាលមកបច្ចុប្បន្នកាលហ្នឹងវាមាន លក្ខណៈខុសគ្នាម៉េចដែរ?

ខៈបើនិយាយពីទូចឬក៏ពីធំហើយ?

កៈទាំងអស់ហ្នឹងតើពីមុនមកវាម៉េចឥឡូវហ្នឹងវាម៉េច?

ខ៖បើនិយាយពីរឿងអើអតីតកាលវិញពីតូចញ៉ុមគិតថាបច្ចុប្បន្នហ្នឹងវាល្អជាងដោយសារយើង ដឹងក្តីហើយ យើងមានការងារអីធ្វើត្រឹមត្រូវប្រាកដជាល្អនៅជាងពីតូចហើយ។

ក៖ចាំហើយម៉េចដែរដូចជាពីមុនពិបាកមែនទេ?

ខ៖ហ្នឹងហើយជីវភាពពេលមុនពិបាក។

ក៖ចឹងសំរាប់!!ចាំដល់ពេលឥឡូវ?

ខ៖រាងធូរធារហើយ តែមុខចាស់។

ក៖ចឹងម្តាយរបស់បងប្រកបមុខរបរអីគេដែរ?

ខ៖ឥឡូវគាត់គាត់រាងចាស់ហើយធ្វើអីក៏មិនកើតដែរគាត់នៅផ្ទះនៅមើលថែរក្សាផ្ទះសម្បែងកូន។

ក៖ចាំ!!ហ្នឹងហើយចឹងតើសំរាប់អើអ្វីដែលបងចងចាំជាងគេនៅក្នុងជីវិតមួយហ្នឹងហើយ ហើយ មែនទេ?

ខ៖បាទ៎!!!

ក៖ចឹងតើក្តីសង្ឃឹមរបស់បងនៅក្នុងជីវិតថាតើនៅថ្ងៃអនាគតបងចង់បានស្ថានភាពគ្រួសារម៉េចដែរ?

ខ៖ដូចជាអ្វីដែលញ៉ុមបានប្រាប់កញ្ញាដូចពីសំនួរមុន។

ក៖ចាំចឹងតើបងមានពាក្យអ្វីទូន្មានទៅកាន់កូនចៅរបស់បងជំនាន់ក្រោយជាឥឡូវបងអត់ទាន់ មានប្រពន្ធមែនប៉ុន្តែថ្ងៃអនាគតបងនឹងមានហ៎?

ខ៖បាទ!!

ក៖ចឹងអ្វីដែលចង់ទូន្មានទៅកាន់គាត់ ខ្លះ?

ខ៖សំរាប់ញ៉ុមផ្ទាល់ញ៉ុមពេលញ៉ុមមានកូនចៅពេលញ៉ុមទូន្មានវាអោយពួកគាត់ព្យាយាមធ្វើល្អ
នៅក្នុងសង្គមហើយខំរៀនសូត្រហើយជាពិសេសហ្នឹងអោយគាត់ធ្វើតាមព្រះបញ្ញត្តិទាំងឡាយ របស់ព្រះ ព្យាយាមមកវិហារ សំខាន់បំផុតហ្នឹងគឺគាត់ព្យាយាមធ្វើតាមព្រះ
គាត់នឹងទទួលបាន ពរជ័យនៅក្នុងជីវិតរបស់គាត់
នៅលើផែនដីហ្នឹងព្រមទាំងនៅនគរឋានសួគ៌ដែរ។

ក៖ចាំចឹងបងអោយគាត់ជៀសផុតពីផ្លូវម៉េចដែរ?

ខ៖បើនិយាយទៅបើសិនជាគាត់ព្យាយាមធ្វើតាមព្រះបញ្ញត្តិរបស់ព្រះគាត់នឹងងាយស្រួល ដើម្បីគេផុតពីអំពើអាក្រក់ជាច្រើនដូចជាការ សេពគ្រឿងញៀនពីការដើរឈ្លោះទាត់ទែនគ្នា ដើរ បង្ករឿង ផឹកស្រា នឹងមានបញ្ហាដល់គ្រួសារ។

ក៖ចឹងមួយហ្នឹងជាសំនួរមួយចុងក្រោយណាស់បង??

ខ៖បាទ!!

ក៖តើបងមានបទពិសោធន៍អ្វី
ដែលល្អនៅក្នុងជីវិតដែលបងចង់ចែកចាយទៅកាន់កូនចៅរបស់បងហាំ?

ខ៖គឺអើបើនិយាយទៅនេះទាក់ទងនឹងសាសនាគឺញ៉ុមទូន្មានអោយកូនចៅរបស់ខ្ញុំព្យាយាម ធ្វើ តាមដំណឹងល្អរបស់ព្រះ
ព្យាយាមគោរពតាមព្រះបញ្ញាត្តិនឹងអោយពួកគាត់មានការរីកចំរើននឹ
ទទួលពរជ័យពីរព្រះ។

ក៖ចាំអរគុណច្រើនបង
ចឹងបងមានពាក្យអ្វីចុងក្រោយសំរាប់ដួងចិត្តរបស់បងផ្ទាល់បងចង់និ
យាយអ្វីដែលបងចង់និយាយចឹងហាំ?

ខ៖មានចង់និយាយអី!!

ក៖ ដូចជាចង់និយាយអីដែលជាគំនិតរបស់បងជាចង់បញ្ចេញមកឬក៏ចែកចាយទៅកាន់អ្នក ណាគេម្នាក់?

ខ៖អត់ទេអត់ចង់ចែកចាយទេ!!

ក៖ចឹងអត់មានអ្វីបន្ថែមទៀតទេហោ?

ខ៖ហ៊ឺៗ!!!!អរគុណ។

ក៖ចឹងអរគុណច្រើនបងសំរាប់ការចូលរួមនៅក្នុងការសំភាសន៍ជាមួយនឹងខ្ញុំហើយពួកយើង រៀ បចំហើយដាក់វេបសាយ
ដាក់ការសំភាសន៍នេះទៅក្នុងវេបសាយមួយដែលញ៉ុមបានប្រាប់បង
ហើយញ៉ុមអរគុណច្រើនណាបង!!

ខ៖បាទអរគុណច្រើនហើយកញ្ញា។